# សេចក្តីថ្លែងការណ៍រួមលើកទី២
# នៃក្រុមសម្ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល សមាគម នៃសង្គមស៊ីវិលកម្ពុជា

ភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០

កាលពីថ្ងៃទី៩ ខែមិនា ឆ្នាំ២០១០ (មុនមួយថ្ងៃនៃការប្រជុំវិសាមញ្ញរបស់រដ្ឋសភា) ទោះបីជាមានរយៈពេលខ្លីក្នុងការទទួលបាននូវសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយក្តី ក្រុមសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល សមាគម នៃសង្គមស៊ីវិលកម្ពុជា ដែលមានសមាជិកប្រមាណ ២០០ អង្គការ សមាគម បានយកកម្លាំងកាយចិត្តក្នុងកិច្ចប្រឹងប្រែង ស្វះស្វែង ក្នុងការផ្តល់ជាមតិយោបល់ចំពោះភាពខ្វះចន្លោះ សំដៅធ្វើយ៉ាងណាឲ្យសេចក្តីព្រាងច្បាប់បច្ចុប្បន្នជាសេចក្តីព្រាងច្បាប់មួយល្អ បំរើឲ្យសង្គមជាតិ និងប្រជាពលរដ្ឋនៅក្នុងទស្សវត្សនេះ តាមរយៈការពិភាក្សាផ្តល់យោបល់តាមវិទ្យុ ការធ្វើសន្និសីទកាសែត ការប្រគល់លិខិតដែលភ្ជាប់ជាមួយនូវសេចក្តីថ្លែងការណ៍ជូនរដ្ឋសភា ក្នុងគោលបំណងស្នើសុំរដ្ឋសភាពន្យាពេលក្នុងការពិភាក្សា និងអនុម័តទៅលើសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយ និងទុកពេលឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ។

ក្រោយពីការប្រគល់លិខិតដែលភ្ជាប់ជាមួយនូវសេចក្តីថ្លែងការណ៍ ជូនរដ្ឋសភាកម្ពុជា យើងខ្ញុំជាតំណាងក្រុមសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល សមាគម នៃសង្គមស៊ីវិលកម្ពុជាមានការខកចិត្ត និងសោកស្តាយយ៉ាងខ្លាំង ដែលយើងខ្ញុំ មិនមានលទ្ធភាពធ្វើឲ្យរដ្ឋសភាផ្លាស់ប្តូរសេចក្តីសម្រេចចិត្ត ដោយពន្យាពេលពិភាក្សាលើសេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយដ៏មានសារៈសំខាន់មួយនេះ។ ជាថ្មីម្តងទៀត អាស្រ័យទៅតាមពេលវេលាដ៏តិចតួចយើងខ្ញុំ សូមលើកភាពខ្វះចន្លោះ ដែលជាកង្វល់សម្រាប់ធ្វើការពិចារណាមួយចំនួនជូនសារធារណៈជន ក៏ដូចជារាជរដ្ឋាភិបាល និងរដ្ឋសភា ដូចខាងក្រោម៖

១ **ការចូលរួមជាសាធារណៈ** សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយបានចេញផ្សព្វផ្សាយជាសារធាណៈនៅថ្ងៃទី៤ ខែមីនា ពោលគឺនៅចុងសប្តាហ៍ និងចំពេលដែលប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេសប្រារព្ធទិវានារីអន្តរជាតិ ៨មីនា ដោយមិនមានការដាក់ពិគ្រោះយោបល់ជាសាធារណៈ។ ចំពោះក្រុមប្រឹក្សាជាតិ យើងឃើញថា នៅមិនទាន់មានភាពឯករាជ្យ និងពុំមានតំណាងមកពីខាងក្រៅរដ្ឋាភិបាល ហើយក៏ពុំមានការតម្រូវឲ្យក្រុមប្រឹក្សាជាតិនេះ ឬអង្គភាពប្រឆាំងអំពើពុករលួយធ្វើរបាយការណ៍សកម្មភាពការងាររបស់ខ្លួន ដើម្បីឲ្យសាធារណៈជនមានការជឿជាក់ចំពោះស្ថាប័នប្រឆាំងអំពើពុករលួយនេះ និងទទួលខុសត្រូវ ចំពោះសាធារណៈជនផងដែរ។

២ **ការការពារសាក្សី និងអ្នករាយការណ៍** មានភាពទូលំទូលាយមិនច្បាស់លាស់ ដែលជាហេតុធ្វើឲ្យអ្នករាយការណ៍ ឬអ្នកផ្តល់ព័ត៌មាន ឬអ្នកប្តឹងអំពីករណីពុករលួយ អាចជួបប្រទះនូវការគម្រាមកំហែងដល់អាយុជីវិត។ ការតាក់តែងមាត្រានេះមិនបានផ្តល់ការគាំពារជាក់លាក់ ដល់អ្នករាយការណ៍ឬ សាក្សីឡើយ។

៣ **ឯករាជ្យភាពរបស់អង្គភាពប្រឆាំងអំពើពុករលួយ** នៅក្នុងមាត្រានេះយើងពុំឃើញមានការបញ្ជាក់ពីការធានាចំពោះការផ្លាស់ប្តូរ ឬដកចេញនូវតំណែងប្រធានអង្គភាពប្រឆាំងអំពើពុករលួយនោះទេ ហើយយើងទាំងអស់គ្នាក៏បានដឹងថាការងារអង្គភាពប្រឆាំងអំពើពុករលួយមានភាពរសើបខ្លាំងខាងផ្នែកនយោបាយ ហេតុដូច្នេះត្រូវធានាឲ្យបានថាប្រធានអង្គភាពប្រឆាំងអំពើពុករលួយមិនទទួលសម្ពាធនយោបាយឡើយ។ ទន្ទឹមនឹងនេះ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយត្រូវតែមានការងារ ឬការទទួលខុសត្រូវតែមួយ ជាងនេះទៅទៀត ប្រធានអង្គភាពប្រឆាំងអំពើពុករលួយត្រូវតែជាបុគ្គលដែលបានការជឿទុកចិត្តពីសាធារណៈជនថាជាបុគ្គលឯករាជ្យ និងស្ថិតនៅពីលើផុតពីកិច្ចការនយោបាយផងដែរ។

៤ **ការពិនិត្យមើល** តើអ្នកណាជាអ្នកពិនិត្យមើល ដើម្បីប្រាកដថាអង្គភាពប្រឆាំងអំពើពុករលួយមានការទទួលខុសត្រូវចំពោះតួនាទីរបស់ខ្លួន។ ក្រុមប្រឹក្សាជាតិត្រូវពិនិត្យមើល ឬធ្វើសវនកម្មលើពាក្យបណ្តឹងទាំងឡាយណា ដែលអង្គភាពប្រឆាំងអំពើពុករលួយបានទទួល ហើយសម្រេចថាមិនធ្វើការស៊ើបអង្កេត។ ក្រុមប្រឹក្សាជាតិ ក៏ត្រូវពិនិត្យមើលផងដែរលើរបាយការណ៍ស៊ើបអង្កេតទាំងឡាយណា ដែលមិនបានបញ្ជូនទៅដល់តុលាការជំនុំជំរះ ក៏ប៉ុន្តែមិនត្រូវដឹង ឬលូកលាន់ក្នុងកំឡុងពេលដែលការស៊ើបអង្កេតកំពុងដំណើរការ ។

៥ **ឯករាជ្យភាពថវិកា** ក្នុងនេះត្រូវបញ្ជាក់ច្បាស់លាស់ថាតើអ្នកណាជាអ្នកត្រួតពិនិត្យកញ្ចប់ថវិកា។ ត្រូវមានបញ្ជាក់ច្បាស់លាស់អំពីកំរិតថវិកា មានតិចបំផុតប៉ុន្មាន និងធានាថាថវិកានេះមិនកាត់បន្ថយពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីប្រាកដ និងធានាថាក្រុមប្រឹក្សាជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយមានថវិកាគ្រប់គ្រាន់ក្នុងការអនុវត្តការងាររបស់ខ្លួនពេញលេញ។

៦ **ការប្រកាសទ្រព្យសម្បត្តិ** ដើម្បីប្រាកដថាអង្គភាពប្រឆាំងអំពើពុករលួយមានសមត្ថភាពពេញលេញ និងគ្រប់គ្រាន់ក្នុងការបំពេញការងាររបស់ខ្លួន ការប្រកាសទ្រព្យសម្បត្តិ គួរតែផ្តោតជាសំខាន់ចំពោះមន្ត្រីជាន់ខ្ពស់នៃរដ្ឋាភិបាលជាជាងផ្តោតលើមន្ត្រីទូទៅគ្រប់លំដាប់ និងមន្ត្រីអង្គការមិនមែនរដ្ឋាភិបាល។ ដើម្បីឲ្យមានន័យគ្រប់គ្រាន់ មាត្រាស្តីពីការប្រកាសទ្រព្យសម្បត្តិ គប្បីបញ្ចូលផងដែរនូវសហព័ទ្ធ និងកូនរបស់មន្ត្រីជាន់ខ្ពស់ទាំងនោះ។ ច្បាប់នេះក៏គប្បីដាក់បញ្ចូលផងដែរនូវប្រយោគគ្របដណ្តប់ទ្រព្យទាំងឡាយណាដែលស្ថិតនៅក្នុងគោលដៅត្រួតពិនិត្យ។

៧ **អំណោយ** មិនទាន់បានកំណត់និយមន័យច្បាស់លាស់។ ពាក្យ **ប្រពៃណី** មិនគួរគប្បីធ្វើជារបាំងការពារឡើយ។ បើទោះបីវាជាទម្លាប់ក្នុងការផ្តល់អំណោយនៅក្នុងប្រទេសកម្ពុជាក៏ដោយ ក៏ច្បាប់គប្បីកំណត់ឲ្យច្បាស់ពីកម្រិត និងបរិមាណនៃអំណោយ។ ប្រទេសកម្ពុជាគប្បី ក្រឡេកមើលច្បាប់ប្រឆាំងអំពើពុករលួយរបស់ហុងកុង ដែលកំណត់ឲ្យផ្តល់អំណោយត្រឹមចំនួន មួយរយដុល្លាតែប៉ុណ្ណោះ។

៨ **អំពើពុករលួយតូចតាច** មិនអាចនិយាយថាដើម្បីរស់ ការប្រព្រឹត្តិអំពើពុករលួយអាចទទួលយកបាននោះទេ យើងទាំងអស់គ្នាដឹងថា គ្រូបង្រៀន ប៉ូលីស បុគ្គលិកសុខាភិបាល និងមន្ត្រីរាជការដទៃទៀត ទទួលបានប្រាក់បៀវត្សន៍តិចតួច ដូច្នេះតើអ្នកទាំងនោះអាចនឹងមានលេសជាផ្លូវការក្នុងការប្រព្រឹត្តិអំពើពុករលួយដើម្បីរស់ឬ?

៩ **ការមានបានមិនប្រក្រតី** ហេតុអ្វីបានជាច្បាប់អនុញ្ញាតិឲ្យមនុស្សមានបានដោយមិនប្រក្រតីលាក់បាំងអំពើពុករលួយរបស់ខ្លួន? នៅក្នុងសេចក្តីព្រាងច្បាប់នេះ អ្វីដែលជនពុករលួយត្រូវធ្វើគឺត្រូវប្រកាសពីទ្រព្យសម្បត្តិដែលបានមកដោយមិនប្រក្រតីនៅក្នុងទម្រង់ប្រកាសទ្រព្យសម្បត្តិ។ ផ្ទុយទៅវិញ បទល្មើសស្តីពីការមានបានដោយមិនប្រក្រតី គប្បីជួយដល់ការកាត់ទោសអ្នកប្រព្រឹត្តិអំពើពុករលួយ នៅពេលដែលមានការលំបាកក្នុងការរកភស្តុតាងជាក់ស្តែងនៃអំពើពុករលួយ ហើយប្រការដែលពួកគេមានទ្រព្យសម្បត្តិមិនអាចពន្យល់បាននោះ គឺជាការសន្មត់ថាទ្រព្យទាំងនោះបានមកពីប្រភពពុករលួយ។

១០ **ការកែទម្រង់ទូលំទូលាយបំថែមទៀតនូវរដ្ឋបាលសារធារណៈនិងដំណើរការលទ្ធកម្ម ដើម្បីបញ្ជ្រាបការប្រឆាំងអំពើពុករលួយ** ហេតុអ្វីបានជាបទបញ្ញតិទាំងនេះ ត្រូវបានដកចេញ? នៅក្នុងសេចក្តីព្រាងចាស់ មានចែងអំពីក្របខ័ណ្ឌដ៏ទូលំទូលាយមួយដើម្បីលើកកម្ពស់តម្លាភាព និងបញ្ជ្រាបការប្រឆាំងអំពើពុករលួយទូទាំងរដ្ឋាភិបាល។ តើតើហេតុអ្វីបានជាគោលការណ៍ទាំងនេះត្រូវបានដកចេញ?

ថ្វីត្បិតតែ យើងខ្ញុំមានកង្វល់ជាច្រើនដូចបានរៀបខាងលើក្តី យើងខ្ញុំនៅរំពឹងជាចុងក្រោយថា រាជរដ្ឋាភិបាលនឹងផ្តោតសំខាន់ក្នុងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយនេះឲ្យមានប្រសិទ្ធភាព ដើម្បីភាពសុខដុមរម្យនារបស់ប្រជាពលរដ្ឋ ជាម្ចាស់ឆ្នោត និងភាពចំរើនរុងរឿងរបស់ប្រទេសជាតិ សំដៅលើកកម្ពស់និងពង្រឹងអភិបាលកិច្ចល្អ សិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងយុត្តិធម៌សង្គម កាន់តែមានភាពប្រសើរថែមទៀត។ ទន្ទឹមនឹងនេះយើងខ្ញុំ មានសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលនឹងពិចារណាធ្វើវិសោធនកម្មលើច្បាប់នេះ នៅពេលដែលរដ្ឋាភិបាលជួបឧបសគ្គនាពេលអនុវត្ត ឬមើលឃើញ និងទទួលស្គាល់ថាច្បាប់នេះ មិនមានប្រសិទ្ធិភាពគ្រប់គ្រាន់ ក្នុងការចាត់វិធានការណ៍ចំពោះជនពុករលួយទាំងឡាយណា ដែលជាឧបសគ្គដល់ការអភិវឌ្ឍប្រទេសជាតិ។

នេះជាជំហរ និងកង្វល់របស់យើងខ្ញុំ ជាតំណាងក្រុមសម្ព័ន្ធ អង្គការមិនមែនរដ្ឋាភិបាល សមាគម នៃសង្គមស៊ីវិលកម្ពុជា ពោលគឺជាជំហររិះគន់ក្នុងន័យស្ថាបនា នៅក្នុងក្របខ័ណ្ឌនៃតួនាទីរបស់ខ្លួនជាសង្គមស៊ីវិល នៃរបបប្រជាធិបតេយ្យ និងក្នុងន័យចូលរួមចំណែកក្នុងការកសាងប្រទេសឲ្យមានភាពរុងរឿង ។

សេចក្តីថ្លែងការណ៍រួមនេះចេញដោយក្រុមសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល សមាគម នៃសង្គមស៊ីវិលកម្ពុជាមានជាអាទ៍ដូចជាៈ សម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម (CISA) ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) សមាគមអាដហុក (ADHOC) អង្គការលីកាដូ (LICADHO) NGO CEDAW គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគម ការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO FORUM) គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL) អង្គការសីលការ (SILAKA) វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) ។

*សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងជាមួយៈ*

| | | | |
|---|---|---|---|
| ១ | លោក **សុក សំអឿន** | នាយកប្រតិបត្តិក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) និងជាប្រធានសម្ព័ន្ធដើម្បីសុចរិតភាព និង គណនេយ្យភាពសង្គម (CISA) | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| ២ | លោក **ធន សារាយ** | ប្រធានសមាគមអាដហុក (ADHOC | ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩ |
| ៣ | លោកស្រី**ពុង ឈីវកេក** | ប្រធានអង្គការលីកាដូ (LICADHO) និងជាប្រធាន NGO CEDAW | ទូរស័ព្ទលេខ: ០១២ ៨០២ ៥០៦ |
| ៤ | លោកស្រី **ធីតា ឃឹះ** | នាយកប្រតិបត្តិអង្គការសីលកា(SILAKA) | ទូរស័ព្ទលេខ: ០១២ ៨៣៨ ៤៦៤ |
| ៥ | លោក **ហង្ស ឆាយា** | នាយកប្រតិបត្តិKID និងជាប្រធានសម្របសម្រួល CHRAC | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| ៦ | លោក **ឈិត សំអាត** | នាយកប្រតិបត្តិអង្គការ NGO FORUM | ទូរស័ព្ទលេខ: ០១២ ៩២៨ ៥៨៥ |
| ៧ | លោក **គល់ បញ្ញា** | នាយកប្រតិបត្តិ (COMFREL) | ទូរស័ព្ទលេខ: ០១២ ៩៤២ ០១៧ |
| ៨ | លោក **អ៊ូ វីរៈ** | ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) | ទូរស័ព្ទលេខ: ០១២ ៤០៤ ០៥១ |